**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ
លេខ ០១៤៦ មជអសក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧

## ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

## សូមជម្រាបជូន

## លោក-លោកស្រីវេជ្ជបណ្ឌិត និងគ្រូពេទ្យព្យាបាលជំងឺអេដស៍
## នៅតាមសេវាថែទាំព្យាបាលជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ ក្មេងជំទង់ និងកុមារ

**កម្មវត្ថុ:** ការណែនាំអំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ការណាត់ជួបអ្នកជំងឺអេដស៍ និងការកំណត់អំពីអ្នកជំងឺបោះបង់ការព្យាបាល (Lost to follow up) ។

*យោង:*
- *គោលការណ៍ណែនាំជាតិ ស្តីពីការគ្រប់គ្រងគ្លីនិក និងព្យាបាលជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ និង ក្មេងជំទង់ ដែលបានអនុម័តដោយក្រសួងសុខាភិបាលចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦។*
- *គោលការណ៍ណែនាំជាតិ ស្តីពីការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើកុមារ និងក្មេងជំទង់ ដែលបានអនុម័តដោយក្រសួងសុខាភិបាលចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦។*
- *គោលការណ៍ណែនាំរួម ស្តីអំពី ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ សម្រាប់ព្យាបាល និង បង្ការការឆ្លងមេរោគអេដស៍ របស់អង្គការសុខភាពពិភពលោក ឆ្នាំ២០១៦*
  *(Consolidated Guidelines on the use of Antiretroviral Drugs for Treating and Preventing HIV Infection-WHO, 2016).*
- *គោលការណ៍ណែនាំរួម ស្តីអំពី សេវាធ្វើតេស្តរកមេរោគអេដស៍ របស់អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥*
  *(Consolidated guidelines on HIV Testing Services - WHO, 2015 )*
- *គោលការណ៍ណែនាំរួម ស្តីអំពី ព័ត៌មានយុទ្ធសាស្ត្រ សំរាប់ ជំងឺអេដស៍ ក្នុងវិស័យសុខាភិបាល របស់អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥*
  *(Consolidated Strategic Information guidelines for HIV in the health sector- WHO, 2015 )*

ន័យដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សូមធ្វើការណែនាំដល់គ្រប់សេវាថែទាំព្យាបាលជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ និងកុមារ ដូចខាងក្រោម៖

## ១. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយពុំចាំបាច់ រង់ចាំលទ្ធផលតេស្ត $CD_4$ នោះទេ ព្រោះការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អាចធ្វើបានដោយមិនគិតពីកម្រិតកោសិកា $CD_4$ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវធ្វើតេស្ត $CD_4$ មុននឹងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដើម្បីធ្វើជាទិន្នន័យមូលដ្ឋានសម្រាប់តាមដានជំងឺអេដស៍ និងសម្រេចចិត្តចាប់ផ្តើម ឬ បញ្ឈប់ការព្យាបាលបង្ការជំងឺឱកាសនិយម។
- ចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលបានចុះឈ្មោះក្នុងបញ្ជី Pre-ART រួមទាំងអ្នកដែលទើបរកឃើញថ្មី តាមរយៈការធ្វើតេស្តអង្គបដិបក្ខប្រាណប្រឆាំងមេរោគអេដស៍ (HIV antibody test) ត្រូវតែធ្វើតេស្តបញ្ជាក់ឡើងវិញ ម្តងទៀតនៅសេវា VCCT ដោយប្រើពិធីសារពេញលេញរបស់ VCCT (តេស្តរហ័សទាំង៣) មុននឹងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ បើលទ្ធផលតេស្តបញ្ជាក់នេះ អវិជ្ជមាន នោះពុំត្រូវ ផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទេ។
- ចំពោះអ្នកជំងឺដែលមានស្ថានភាពល្អ (Stable patient) អាចផ្តល់ឱសថ ARVs រយៈពេល ៣ខែ ឬ យូរជាងនេះ ទៅតាមស្ថានភាពឱសថ ARVs ដែលមានក្នុង stock។ អ្នកជំងឺដែលត្រូវចាត់ទុកថា មាន ស្ថានភាពល្អត្រូវមានលក្ខណៈដូចខាងក្រោម៖
  - បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ យ៉ាងតិចរយៈពេល ១ឆ្នាំ ***និង***
  - ពុំមានប្រតិកម្មបង្កដោយឱសថ ដែលតម្រូវឲ្យមានការតាមដានទៀងទាត់ ***និង***
  - ពុំមានផ្ទៃពោះ ឬស្ថិតក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយ ***និង***
  - មិនមានជំងឺផ្សេងទៀតដែលតម្រូវអោយមានការតាមដាន ***និង***
  - មានការយល់ដឹងល្អ អំពី ការលេបថ្នាំឱ្យ បានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់មួយជីវិត ***និង***
  - ទទួលបានជោគជ័យក្នុងការព្យាបាលដោយមានលទ្ធផលតេស្ត Viral load ២ដងចុងក្រោយ តិចជាង 1000 copies /ml ។
- ឱសថ ARVs បំរុង (buffer) ត្រូវផ្តល់ជូនអ្នកជំងឺសំរាប់រយៈពេលមិនឱ្យលើសពី ៥ ថ្ងៃទេ

## ២. ការណាត់ជួបអ្នកជំងឺ និងការកំណត់អំពីអ្នកជំងឺបោះបង់ការព្យាបាល

រយៈពេលនៃការណាត់ជួបអ្នកជំងឺអាស្រ័យលើសភាពរបស់អ្នកជំងឺ និង ភាពចាំបាច់ក្នុងការតាមដានការព្យាបាល៖

- ចំពោះអ្នកជំងឺដែលមានស្ថានភាពល្អ (stable patient) ត្រូវណាត់ជួប រយៈពេល ៣ខែ ឬ យូរជាងនេះ ប៉ុន្តែមិនត្រូវលើសពីរយៈពេល ៦ខែទេ។
- ត្រូវចាត់ទុកថា អ្នកជំងឺបោះបង់ការព្យាបាល បើសិនបើអ្នកជំងឺមិនមកទទួលសេវាលើសពី ៩០ថ្ងៃ បន្ទាប់ពីមិនបានមក តាមថ្ងៃណាត់ជួបចុងក្រោយ (next appointment) ។ ទោះបីយ៉ាងណាក៏ដោយ កន្លែងផ្តល់សេវា ART ទាំងអស់ ត្រូវមានយន្តការជាស្រេច ដើម្បីទាក់ទងភ្លាមៗ ទៅ អ្នកជំងឺ ដែល មិនបានមកតាមការណាត់ជួប។
- ចំពោះអ្នកជំងឺដែលបោះបង់ការព្យាបាល ហើយត្រឡប់មកទទួលការព្យាបាលវិញ អាចចាប់ផ្តើម ART ឡើងវិញដោយប្រើ ARV-regimen ដែលគាត់ធ្លាប់ទទួលមុនបោះបង់ការព្យាបាល (លើកលែងតែក្នុងករណី

ដឹងថាអ្នកជំងឺមានប្រតិកម្មទៅនឹង ARV regiment) និងត្រូវធ្វើតេស្ត Viral load នៅ ៣ខែបន្ទាប់ពីបានចាប់ផ្តើម ART ឡើងវិញ។

អាស្រ័យហេតុនេះសូមលោក-លោកស្រីវេជ្ជបណ្ឌិត និងគ្រូពេទ្យព្យាបាលនៃសេវាថែទាំ ព្យាបាលជំងឺអេដស មេត្តាអនុវត្តតាមការណែនាំខាងលើ ឲ្យមានប្រសិទ្ធភាពដើម្បីលើកកំពស់គុណភាពសេវាថែទាំព្យាបាលអ្នកជំងឺអេដស៍នៅកម្ពុជា។

សូមលោក-លោកស្រីមេត្តា ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

វេជ្ជ.លី-ពេញ ស៊ុន

***ចម្លងជូន:***

- *ប្រធានមន្ទីរសុខាភិបាលខេត្ត-រាជធានី*
- *ប្រធានកម្មវិធីអេដស៍និងកាមរោគខេត្ត-រាជធានី*
- *ប្រធានមន្ទីរពេទ្យដែលមានសេវា ART*
- *ឯកសារកាលប្បវត្តិ*